ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
លេខ ២៧២ ប្រក.ក.........

# ប្រកាស
## ស្តីពី
## ក្រមសីលធម៌របស់មតិកមនុស្សរស់

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០២១០/១៦៣ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១០ ស្តីពី ប្រព័ន្ធមតិកមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- តាមការចាំបាច់របស់ក្រសួង

## សម្រេច
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.**

ប្រកាសនេះមានគោលដៅកំណត់អំពី ក្រមសីលធម៌របស់មតិកមនុស្សរស់ក្នុងគោលបំណងលើកកម្ពស់អត្តចរិត សីលធម៌ សេចក្តីថ្លៃថ្នូរ និងកិត្តិយស ក្នុងក្របខណ្ឌវិជ្ជាជីវៈមតិកមនុស្សរស់ ដើម្បីថែរក្សា ការពារបេតិកភណ្ឌវប្បធម៌អរូបីរបស់ជាតិឲ្យបានគង់វង្ស ។

**ប្រការ២.**

ប្រកាសនេះ មានវិសាលភាពគ្របដណ្តប់លើពលរដ្ឋខ្មែរទូទៅ ដែលត្រូវបានជ្រើសរើស និងទទួល ស្គាល់ជាមតិកមនុស្សរស់ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី២
## គោលការណ៍គ្រឹះ

**ប្រការ៣.**

ក្រមសីលធម៌នេះ កំណត់នូវគោលការណ៍គ្រឹះសំខាន់ ៣ សម្រាប់មតិកមនុស្សរស់អនុវត្ត ៖

-មតិកមនុស្សរស់ត្រូវប្រកាន់ខ្ជាប់នូវវិន័យក្នុងការប្រកបមុខរបរវិជ្ជាជីវៈ

-មតិកមនុស្សរស់ត្រូវគោរពលក្ខខណ្ឌដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនានា ដើម្បីផលប្រយោជន៍សង្គមនិងរក្សាឲ្យបាននូវអត្តសញ្ញាណជាតិ

-មតិកមនុស្សរស់ ត្រូវប្រកាន់ខ្ជាប់នូវឥស្សរភាពនៃវិជ្ជាជីវៈដែលមានជាអាទិ៍ៈឯករាជ្យ សន្តិភាព សេរីភាព និងឧត្តមភាព ក្នុងការបំពេញវិជ្ជាជីវៈរបស់ខ្លួនដើម្បីរក្សាឲ្យបាន នូវកិត្យានុភាពវប្បធម៌ជាតិ ។

## ផ្នែកទី៣
## ករណីយកិច្ចរបស់មតិកមនុស្សរស់

**ប្រការ៤.**

មតិកមនុស្សរស់ត្រូវរក្សាឲ្យបាននូវតម្លៃសីលធម៌ វិន័យការងារ គោរពច្បាប់ និងភាតព្វកិច្ច ដែលត្រូវបំពេញឲ្យបានស័ក្តិសមទៅនឹងកិត្តិយសដែលទទួលបាន ។

**ប្រការ៥.**

មតិកមនុស្សរស់ ត្រូវហ៊ានលះបង់ប្តូរផ្តាច់ដើម្បីថែរក្សា ការពារនូវ ចំណេះដឹង ជំនាញ ទេពកោសល្យ បច្ចេកទេសរបស់ខ្លួនមិនឲ្យបាត់បង់ ទោះក្នុងស្ថានភាពលំបាកបែបណាក៏ដោយ ។

**ប្រការ៦.**

មតិកមនុស្សរស់ត្រូវយកអស់កម្លាំងកាយចិត្ត និងប្រាជ្ញាដើម្បីផ្សព្វផ្សាយនិងបណ្តុះបណ្តាល ចំណេះជំនាញរបស់ខ្លួនដល់អ្នកបន្តវេនដោយឥតលាក់លៀម ។

**ប្រការ៧.**

មតិកមនុស្សរស់ត្រូវប្តូរផ្តាច់ចងក្រង ស្នាដៃ ក្បួនច្បាប់ ចំណេះជំនាញ ជូនក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈ សម្រាប់រក្សាទុកជាកេរមតិកជាតិ ហើយស្នាដៃនោះត្រូវបានការពារដោយច្បាប់ស្តី ពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ។

**ប្រការ៨.**

មតិកមនុស្សរស់ត្រូវរក្សាទំនាក់ទំនងសាមគ្គីភាពល្អ និងត្រូវធ្វើជាគំរូក្នុងឥរិយាបថ អាកប្បកិរិយា និងពាក្យសម្ដីជាមួយគ្រប់មជ្ឈដ្ឋាន ។

**ប្រការ៩.**

មតិកមនុស្សរស់ ត្រូវគោរពតាមកាតព្វកិច្ចរបស់ខ្លួន ដែលមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១០/១៦៣ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០ ស្ដីពី ប្រព័ន្ធមតិកមនុស្សរស់ នៃព្រះរាជាណាចក្រកម្ពុជា និង តាមគោលការណ៍កំណត់នៃក្រមសីលធម៌វិជ្ជាជីវៈសិល្បករ ។

**ប្រការ១០.**

មតិកមនុស្សរស់មិនត្រូវយកគោរមងារ និងភាពល្បីល្បាញរបស់ខ្លួនទៅគាបសង្កត់ ឬបង្កើតបញ្ហាអ្វី មួយដល់អ្នកដទៃ និងសង្គមជាតិ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**ប្រការ១១.**

បុគ្គល ឬ ក្រុម ដែលបានទទួលគោរមងារជាមតិកមនុស្សរស់ មានភារកិច្ចត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈនេះ ។

**ប្រការ១២.**

នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រ សិល្បៈ គ្រប់ប្រធាននាយកដ្ឋានអង្គភាពពាក់ព័ន្ធ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត និងប្រធានគណៈកម្មាធិការមតិកមនុស្សរស់ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ[illegible] ឆ្នាំ២០១០

រដ្ឋមន្ត្រី

ហ៊ឹម ឆែម

កន្លែងទទួល:

- -ទីស្ដីការគណៈរដ្ឋមន្ត្រី
- -គ្រប់ក្រសួង-ស្ថាប័ន
- -ដូចប្រការ១២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ